Washington State Department of
CHILDREN, YOUTH & FAMILIES

# លិខិតជូនដំណឹង និងការយល់ព្រមចំពោះការវាយតម្លៃ/ការប៉ាន់ប្រមាណ

**គោលបំណង៖** ដើម្បីផ្តល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់មាតាឬបិតានៅពេលការវាយតម្លៃ/ការប៉ាន់ប្រមាណត្រូវបានស្នើសុំ និងទទួលការយល់ព្រមពីមាតាបិតាដើម្បីអនុវត្តការវាយតម្លៃ/ការប៉ាន់ប្រមាណដែលបានស្នើសុំ.

| ឈ្មោះកូន | ថ្ងៃខែឆ្នាំកំណើត | អ្នកសម្របសម្រួលធនធានគ្រួសារ |
|---|---|---|
| | | |

**មូលហេតុចំពោះលិខិតដំណឹង**
កម្មវិធី ESIT តម្រូវឱ្យផ្តល់ជូនលោកអ្នកនូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដែលមានរយៈពេលសមរម្យមុនការអនុវត្តសកម្មភាពនៃការវាយតម្លៃ និងការប៉ាន់ប្រមាណ។ វាតម្រូវឱ្យលោកអ្នកផ្តល់ជូនការយល់ព្រមជាលាយលក្ខណ៍អក្សរដែលបានជូនដំណឹងសម្រាប់សកម្មភាពទាំងនេះតាមរយៈហត្ថលេខារបស់អ្នកខាងក្រោម។។ គោលបំណងនៃការវាយតម្លៃ និងការប៉ាន់ប្រមាណ គឺដើម្បីទទួលបានព័ត៌មានអំពីកូនរបស់អ្នក, ផ្តល់ជូនព័ត៌មានបន្ថែមអំពីក្រុមគ្រួសាររបស់អ្នកអំពីការវិវត្តន៍កូនរបស់អ្នក; កំណត់ភាពខ្លាំងតែមួយគត់ និងតម្រូវការកូនរបស់អ្នកនិងសេវាកម្មនានាដែលអាចសមស្របដើម្បីបំពេញតម្រូវការទាំងនោះ; កំណត់ថាតើកូនរបស់អ្នកមានសិទ្ធិទទួលបានកម្មវិធី ESIT ឬអត់; ហើយប្រសិនបើកូនរបស់អ្នកមានសិទ្ធិស្របច្បាប់ដោយមានការយល់ព្រមនិងការចូលរួមរបស់អ្នក បង្កើតឬកែតម្រូវផែនការសេវាកម្មក្រុមគ្រួសារដែលមានលក្ខណៈបុគ្គលដែលសរសេរជាលាយលក្ខណ៍អក្សរ (IFSP)។ ហើយនេះជារបាយការណ៍របស់អ្នកអំពីលិខិតជូនដំណឹងនោះ។នោះ។

ការយល់ព្រម""មានន័យថា៖ *(1)* អ្នកត្រូវបានគេជូនដំណឹងយ៉ាងពេញលេញអំពីព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹង *ac*សកម្មភាពដែលក្នុងនោះការយល់ព្រម ត្រូវបានស្វែងរកជាភាសាកំណើតរបស់អ្នក ឬរបៀបប្រាស្រ័យទាក់ទង, ដែលរួមមាន, អក្សរសម្រាប់មនុស្សខ្វាក់ ឬឬការប្រាស្រ័យ ទាក់ទងដោយផ្ទាល់មាត់ដែលសមស្រប។. 2) ដែលលោកអ្នកយល់ដឹងនិងយល់ព្រមជាលាយលក្ខណ៍អក្សរចំពោះការអនុវត្តសកម្មភាព ដែលក្នុងនោះការយល់ព្រមត្រូវ បានស្វែងរករក; (3) ការយល់ព្រមពិពណ៌នាអំពីសកម្មភាពនិងរាយបញ្ជីកត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូង (ប្រសិនបើមាន) ដែលនឹងត្រូវបញ្ចេញឱ្យដឹងព័ត៌មាន និងព័ត៌មានដែលត្រូវបញ្ចេញឱ្យជូនទៅអ្នកនោះ; និង (4) ការផ្តល់ជូនការយល់ព្រមរបស់អ្នកគឺជាការស្ម័គ្រចិត្ត ហើយអាចដកចេញដោយសរសេរជាលាយលក្ខណ៍អក្សរបានគ្រប់ពេលវេលា។ ប្រសិនបើលោកអ្នកដកចេញការយល់ព្រមនោះវាមិនមានសកម្មភាពឡើងវិញឡើយ (វាមិនអនុវត្តចំពោះសកម្មភាពដែលបានកើតឡើងមុនការយល់ព្រមនេះត្រូវបានដកចេញវិញឡើយ)។

**វិធានការដែលបានស្នើសុំ**
ការវាយតម្លៃនិងការប៉ាន់ប្រមាណនឹងត្រូវអនុវត្តដោយបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់យ៉ាងតិចចំនួនពីរនាក់មកពីផ្នែកអប់រំផ្សេងគ្នាឬអ្នកជំនាញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកពីផ្នែកអប់រំចំនួនពីរ) ស្របតាមគោលនយោបាយនិងនីតិវិធីនៃកម្មវិធី ESIT។ ការចូលរួមរបស់អ្នកជាសមាជិកក្រុមការងារវាយតម្លៃ ត្រូវបានជម្រុញលើកទឹកចិត្តយ៉ាងខ្លាំង។ លោកអ្នកយល់ដឹងអំពីកូនរបស់អ្នកយ៉ាងល្អបំផុត ហើយអាចផ្តល់ព័ត៌មានសំខាន់ៗអំពីកូនរបស់អ្នក។ ការវាយតម្លៃនិងការប៉ាន់ប្រមាណគឺជាទស្សនៈទូលំទូលាយមួយអំពីរបៀបដែលកូនរបស់អ្នកកំពុងអនុវត្តមុខវិជ្ជាផ្នែកការចងចាំចលនាដៃជើងនិងរាងកាយ ជំនាញប្រើដៃ ការប្រាស្រ័យទាក់ទង ការវិវត្តន៍ផ្នែកសម្របខ្លួន ផ្លូវចិត្តនិងសង្គម ដូចជាចក្ខុឬការមើលឃើញ និងការស្តាប់ផងដែរ។ លទ្ធផលនានាបង្ហាញពីរបៀបដែលកូនរបស់អ្នកកំពុងអនុវត្តមុខវិជ្ជាគ្រប់ផ្នែកទាំងនេះ ហើយប្រសិនបើកូនរបស់អ្នកបន្តមានសិទ្ធិទទួលបានសេវាកម្ម ESIT ។

**ការពិពណ៌នា**
ការវាយតម្លៃដែលបានស្នើឡើងនឹងរាប់បញ្ចូលនីតិវិធីជាច្រើន ដែលរួមមានការគ្រប់គ្រងវិធីសាស្ត្រវាយតម្លៃ ការទទួលយកប្រវត្តិរបស់កុមារ ការស ង្កេតឪពុកម្តាយ ការប្រមូលព័ត៌មានពីសមាជិកគ្រួសារអ្នកមើលថែទាំ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ឬអ្នកជំនាញផ្សេងទៀត និង ការពិនិត្យឡើងវិញនូវកំណត់ត្រាវេជ្ជសាស្ត្រ អប់រំ ឬកំណត់ត្រាផ្សេងទៀត។ នីតិវិធីវាយតម្លៃដែលបានស្នើសុំនឹងកំណត់ភាពខ្លាំងតែមួយគត់និងតម្រូវការនិងសេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូងដែលសមរម្យរបស់កូនអ្នក។ កា រវាយតម្លៃនឹងរាប់បញ្ចូល៖ ការពិនិត្យឡើងវិញនូវលទ្ធផលវាយតម្លៃ៖ ការត្រួតពិនិត្យ

ផ្ទាល់ខ្លួនអំពីកូនការកំណត់អត្តសញ្ញាណតម្រូវការរបស់កូនចំពោះមុខវិជ្ជាអភិវឌ្ឍនីមួយៗតាមរយៈការប្រើនីតិវិធីវាយតម្លៃជាផ្លូវការនិងមិនផ្លូវការ។ អ្នកផ្តល់សេវាកម្មនៃកម្មវិធី ESIT នឹងពិភាក្សាជាមួយលោកអ្នកអំពីវិធីសាស្ត្រដែលពួកគេនឹងប្រើប្រាស់សម្រាប់ការវាយតម្លៃ និងការប៉ាន់ប្រមាណនេះ។ វាយតម្លៃ និងការប៉ាន់ប្រមាណនេះនឹងត្រូវផ្តល់ជូនដោយឥតគិតថ្លៃលោកអ្នកឡើយ។ លទ្ធផលត្រូវបានរក្សាទុកនៅក្នុងកំណត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូងរបស់កូនអ្នក។ គ្មានព័ត៌មានអំពីការវាយតម្លៃ និងការប៉ាន់ប្រមាណនឹងត្រូវចែករំលែកជាមួយនរណាម្នាក់ ឬទីភ្នាក់ងារណាមួយក្រៅកម្មវិធី ESIT ឡើយ លុះត្រាតែលោកអ្នកផ្តល់ជូនការយល់ព្រមជាលាយលក្ខណ៍អក្សរដើម្បីធ្វើដូច្នេះ។ ក្រុមការងារកម្មវិធី IFSP នឹងកំណត់ថាតើកូនរបស់អ្នកបន្តមានសិទ្ធទទួលសេវាកម្ម ESIT ឬអត់ ហើយនឹងផ្តល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដែលរាប់បញ្ចូលទាំងសិទ្ធិរបស់អ្នក ដើម្បីជំទាស់នឹងការបញ្ឈប់ភាពមានសិទ្ធិស្របច្បាប់

អក្សរដំបូងនៃឈ្មោះមាតាឬបិតា

| |
|---|
| |

**ការទទួលស្គាល់ និងរបាយការណ៍អំពីការយល់ព្រម**
**ខ្ញុំបាទ/នាងខ្ញុំបានទទួលឯកសារថតចម្លងមួយច្បាប់នៃសិទ្ធិនិងការការពារសុវត្ថិភាពតាមនីតិវិធីរបស់ខ្ញុំ ដែលស្ថិតក្រោមផ្នែក C នៃ IDEA (កម្មវិធីគាំទ្រកុមារនិងទារកចាប់ផ្តើមដំបូងច្បាប់ស្តីពីការអប់រំបុគ្គលដែលមានពិការភាព (IDEA) ផ្នែក C ការការពារតាមនីតិវិធី [សិទ្ធិមាតាឬបិតា]} ដោយមានលិខិតជូនដំណឹងនេះ។**

សិទ្ធិ និងនីតិវិធីការពារ សិទ្ធិតាមនីតិវិធីទាំងនេះ បានពន្យល់ខ្ញុំ ហើយខ្ញុំយល់ដឹងអំពីសិទ្ធិនិងនីតិវិធីទាំងនេះ។ ខ្ញុំបាទ/នាងខ្ញុំយល់ថាការយល់ព្រមរបស់ខ្ញុំគឺការស្ម័គ្រចិត្ត ហើយថាខ្ញុំអាចជ្រើសរើសមិនឱ្យកូនរបស់ខ្ញុំត្រូវបានវាយតម្លៃ/ប៉ាន់ប្រមាណនៅគ្រប់ពេលវេលា បើទោះជាបន្ទាប់ពីបានចុះហត្ថលេខាលើសំណុំបែបបទនេះក៏ដោយ។ ខ្ញុំបាទ/នាងខ្ញុំយល់ថាប្រសិនបើខ្ញុំជ្រើសរើសមិនយល់ព្រមលើការវាយតម្លៃឬការប៉ាន់ប្រមាណនេះ កូនរបស់ខ្ញុំនឹងមិនត្រូវបានត្រូវបានវាយតម្លៃ/ប៉ាន់ប្រមាណឡើយ។

☐ ខ្ញុំផ្តល់ជូន ☐ ខ្ញុំមិនផ្តល់ជូន ការយល់ព្រមដែលបានជូនដំណឹងរបស់ខ្ញុំចំពោះកម្មវិធី ESIT ដើម្បីអនុវត្តសកម្មភាពនានាដែលបានពិពណ៌នាខាងលើ។

កុម្ភៈ 2012

| សរសេរអក្សរពុម្ពឈ្មោះរបស់មាតាឬបិតា | |
|---|---|
| ហត្ថលេខាមាតាឬបិតា | កាលបរិច្ឆេទ |
| បានទទួលដោយឈ្មោះ/ឋានៈ/ទីភ្នាក់ងារ | កាលបរិច្ឆេទ |

*ឯកសារភ្ជាប់៖ ការជួយគាំទ្រចាប់ផ្តើមដំបូងសម្រាប់កម្មវិធីកុមារនិងទារក ច្បាប់ស្តីពីការអប់រំបុគ្គលដែលមានពិការភាព (IDEA) ផ្នែក C ការការពារសុវត្ថិភាពតាមនីតិវិធី [សិទ្ធិមាតាបិតា]*
*កំណត់សម្គាល់៖ មាតាបិតាទទួលបានឯកសារថតចម្លងមួយច្បាប់ពីសំណុំបែបបទនេះ និងឯកសារថតចម្លងដែលមានចុះហត្ថលេខា ត្រូវរាប់បញ្ចូលក្នុងកំណត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូងរបស់កុមារ។*